00978374

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 03 / 2014
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

E304

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៤

ជូនចំពោះ៖ លោក គង់ សុភី
ប្រធានផ្នែកគ្រប់គ្រងតុលាការ

ពី៖ ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន៖ លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង គ្រប់ភាគីទាំងអស់, ផ្នែកគ្រប់គ្រងតុលាការ, អង្គភាពបកប្រែភាសា, អង្គភាពប្រតិចារឹក

កម្មវត្ថុ៖ ការកែតម្រូវប្រតិចារឹក

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលអនុស្សរណៈផ្ទៃក្នុង ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៤ ពីផ្នែកគ្រប់គ្រងតុលាការ (CMS) ស្នើសុំឱ្យអង្គជំនុំជម្រះយល់ព្រមលើនីតិវិធីថ្មី ដែលបានស្នើឡើងសម្រាប់អនុវត្តលើការកែតម្រូវកំហុសនានានៅក្នុងប្រតិចារឹក។ ផ្នែកគ្រប់គ្រងតុលាការក៏បានស្នើសុំមកអង្គជំនុំជម្រះឱ្យចេញសេចក្តីណែនាំជាផ្លូវការមួយស្តីពីការដាក់បញ្ចូលជើងទំព័រនៅក្នុងទំព័រនីមួយៗនៃប្រតិចារឹកដែលបានកែតម្រូវរួច ដោយយោងទៅតាមពាក្យសុំកែតម្រូវប្រតិចារឹក។

២. អង្គជំនុំជម្រះបានពិនិត្យមើលឡើងវិញអំពីនីតិវិធីសម្រាប់អនុវត្តលើការកែតម្រូវប្រតិចារឹកនេះដូចបានរៀបរាប់នៅក្នុងអនុស្សរណៈរបស់ផ្នែកគ្រប់គ្រងតុលាការ។ អង្គជំនុំជម្រះយល់ឃើញថា នីតិវិធីនេះអនុលោមតាមបទប្បញ្ញត្តិជាធរមាន ដែលអនុវត្តចំពោះការកែតម្រូវឯកសារផ្សេងៗនៅក្នុងសំណុំរឿង។ ជាពិសេស អង្គជំនុំជម្រះក៏ស្នើឱ្យដាក់បញ្ចូលជើងទំព័រនៅក្នុង

ប្រតិចារឹកដែលបានកែតម្រូវរួចផងដែរ ដើម្បីឱ្យអ្នកអានបានដឹងថា ប្រតិចារឹកនេះត្រូវបានកែតម្រូវ។ ដូចបានកត់សម្គាល់ដោយផ្នែកគ្រប់គ្រងតុលាការ ប្រតិចារឹកច្បាប់ដើមក៏នឹងត្រូវដាក់សញ្ញាសម្គាល់ឱ្យបានសមស្រប និងរក្សាទុកនៅក្នុងសំណុំរឿងផងដែរ ដើម្បីទុកជាកំណត់ហេតុឯកសារ។

៣. អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ព្រមឱ្យប្រើប្រាស់នីតិវិធីនេះសម្រាប់អនុវត្តលើការកែតម្រូវប្រតិចារឹក ហើយស្នើឱ្យផ្នែកគ្រប់គ្រងតុលាការបំពេញនីតិវិធីស្តីពីការដាក់ប្រតិចារឹកទាំងអស់ដែលបានកែតម្រូវរួចហើយនោះ ចូលទៅក្នុងសំណុំរឿងជាបន្ទាន់។